ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៦២
ចុះថ្ងៃទី១៣-០២-២០១៣
សាលដីកាព្រហ្មទណ្ឌ
លេខ: ៩៨ "ក្រ.ll សវ"
ចុះថ្ងៃទី២៧-១២-២០១៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រិត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០១៣ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- ឯកឧត្តម [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ១៦២ ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០១៣ ដែលមាន:

- ជនជាប់ចោទឈ្មោះ [redacted]សុជាវិទ្ធ ហៅ តុង ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ កើតនៅសង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទីលំនៅសព្វថ្ងៃផ្ទះ [redacted] ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនធ្លាប់ជាប់គុកចំនួន ១ឆ្នាំ ពីបទ លក់អាវុធហាមឃាត់ខុសច្បាប់ ឃាត់ខ្លួនថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០១២ ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៧១៨ តព្រ ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០១២ (ដើមបណ្តឹងឧទ្ធរណ៍)។

<u>ជាប់ចោទពីបទ:</u> <u>រំលោភលើទំនុកចិត្ត</u> និងមិនរាងចាលក្នុងបទមជ្ឈឹមបន្ទាប់ពីផ្តន្ទាទោសបទមជ្ឈឹម ប្រព្រឹត្តនៅចំណុចផ្ទះលេខ ៥៦E₀ ផ្លូវលេខ ១៩ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១ មាត្រា ៣៩២ មាត្រា ៨៨ និងមាត្រា ៩០ នៃក្រមព្រហ្មទណ្ឌ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]គិរីមីនន់ ភេទស្រី អាយុ ៣៣ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ ៧០៤ ផ្លូវជាតិលេខ ២ ក្រុម ៦ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ។





Scanned with CamScanner

## អំពើប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:

កាលពីថ្ងៃទី ១៤ ខែមេសា ឆ្នាំ២០១២ វេលាម៉ោង ១៦ និង០០នាទី ជនរងគ្រោះឈ្មោះ [redacted] គិរីមីនន់ និងឈ្មោះ [redacted] សុធារិទ្ធ ដែលត្រូវជាសង្សារនឹងគ្នាបានជិះ ម៉ូតូមួយគ្រឿងម៉ាក ហុងដាឌុប ៥០ ពណ៌ទឹកប៊ិច ពាក់ស្លាកលេខ ភ្នំពេញ ១AW-១៥១៥ ជាមួយគ្នា ដោយឈ្មោះ [redacted] សុធារិទ្ធ ជាអ្នកឌុប ពេលធ្វើដំណើរមកដល់ចំណុចមុខផ្ទះលេខ ៥៦E₀ ផ្លូវលេខ ១៩ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ក៏ឈប់ម៉ូតូ ហើយជនរងគ្រោះបានចុះទៅទិញបបរស ពេលនោះឈ្មោះ [redacted] សុធារិទ្ធ បានជិះម៉ូតូរបស់ជនរងគ្រោះគេចខ្លួនបាត់។ បន្ទាប់មកឈ្មោះ [redacted] សុធារិទ្ធ បានជិះម៉ូតូនេះទៅជួបឈ្មោះ ឆេង ដើម្បីបញ្ចាំម៉ូតូ ហើយឈ្មោះ ឆេង បានទូរស័ព្ទឲ្យឈ្មោះ ណា ដើម្បីយកប្រាក់ចំនួន ៦០០ដុល្លារ មកប្រគល់ឲ្យឈ្មោះ [redacted] សុធារិទ្ធ ជាថ្លៃបញ្ចាំម៉ូតូ។ លុះដល់ថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០១២ សមត្ថកិច្ចបានឃាត់ខ្លួនឈ្មោះ [redacted] សុធារិទ្ធ រួចកសាងសំណុំរឿងបញ្ជូនមកសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១០១ ឃ ចុះថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ផ្តន្ទាទោសលើឈ្មោះ [redacted] សុធារិទ្ធ ហៅ គុង ភេទប្រុស អាយុ ២៥ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៤(បួន)ឆ្នាំ ពីបទ រំលោភលើទំនុកចិត្ត និងមិនរាងចាលក្នុងបទមជ្ឈិម បន្ទាប់ពីផ្តន្ទាទោសបទមជ្ឈិម ប្រព្រឹត្តនៅចំណុចផ្ទះលេខ ៥៦E₀ ផ្លូវលេខ ១៩ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៤ ខែមេសា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៨៨ មាត្រា ៩០ មាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

២- សាលក្រមនេះជំនុំជម្រះជាសាធារណៈនាថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈនាថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០១២។

បើកផ្លូវឲ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

- បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សុធារិទ្ធ ជាជនជាប់ចោទ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១០១ ឃ ចុះថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រប់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។



Scanned with CamScanner

- បានឃើញរបាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍។

<u>នាពេលសវនាការ</u>

- ជនជាប់ចោទឈ្មោះ [redacted] សុធារិទ្ធ (វត្តមាន)

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] គិរីមីនន់ (អវត្តមាន)

ជនជាប់ចោទឈ្មោះ [redacted] សុធារិទ្ធ ឆ្លើយថា: ខ្លួនប្ដឹងឧទ្ធរណ៍ដោយសារសាលាដំបូងសម្រេចដាក់ទណ្ឌកម្មខ្លួនខ្ពស់ពេកសូមតុលាការសាលាឧទ្ធរណ៍មេត្តាសម្រេចបន្ធូរបន្ថយទោសខ្លួនផង។

តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ធ្វើសេចក្ដីសន្និដ្ឋានថា: មានភស្តុតាងដាក់បន្ទុកនិងពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] សុធារិទ្ធ ដូចបទចោទរបស់អយ្យការសាលាដំបូង (រំលោភលើទំនុកចិត្ត) ត្បិតមានចម្លើយសារភាពរបស់ជនជាប់ចោទច្បាស់លាស់ ស៊ីសង្វាក់គ្នានឹងចម្លើយរបស់ជនរងគ្រោះ។ សាលក្រមរបស់សាលាដំបូងសម្រេចមកនេះត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ហើយ។ ចំពោះទណ្ឌកម្មដែលតុលាការផ្ដន្ទាទោសលើជនជាប់ចោទដាក់ពន្ធនាគារកំណត់ ៤ឆ្នាំ ឃើញថា សមល្មមត្បិតជននេះត្រូវបានចោទប្រកាន់ពីករណីមិនរាងចាល ដែលទណ្ឌកម្មត្រូវទ្វេដង។ ដូច្នេះ គប្បីសភាព្រហ្មទណ្ឌតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១០១ ឃ ចុះថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ។

- ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍
- ក្រោយពីបានពិនិត្យពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

<u>សភាព្រហ្មទណ្ឌ យល់ឃើញថា:</u>

១- បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សុធារិទ្ធ ជាជនជាប់ចោទ សុំប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១០១ ឃ ចុះថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច បានធ្វើឡើងត្រឹមត្រូវក្នុងកំណត់ច្បាប់ សភាព្រហ្មទណ្ឌទទួលជំនុំជម្រះបាន យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- តាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោល ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុធារិទ្ធិ បានឆ្លើយសារភាពទទួលកំហុសរបស់ខ្លួនថា កាលពីថ្ងៃទី ១៤ ខែមេសា ឆ្នាំ២០១២ ខ្លួនពិតជា...



Scanned with CamScanner

បានខ្ចីម៉ូតូរបស់ជនរងគ្រោះយកទៅទិញបារី រួចក៏ជិះយកទៅដាក់បញ្ចាំបានលុយចំនួន ៦៥០ ដុល្លារ ហើយបានបិទទូរស័ព្ទ និងគេចខ្លួនតែម្តង ដែលជាទម្រង់មួយនៃអំពើមានពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទ ពីបទ រំលោភលើទំនុកចិត្ត បំពានមាត្រា ៣៩១ និងមាត្រា ៣៩២ ដែលគប្បីផ្តន្ទាទោសជននេះតាមច្បាប់។

៣- សាលក្រមព្រហ្មទណ្ឌលេខ ១០១ ឃ ចុះថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលសម្រេចមកនេះមានលើកសំអាងហេតុសព្វគ្រប់ និងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គួរសភាព្រហ្មទណ្ឌតម្កល់ទុកជាបានការដដែល ដោយគ្មានការគ្រាប្រណីទោសឡើយ ពីព្រោះជាករណីមិនរាងចាលក្នុងបទមជ្ឈឹម យោងតាមមាត្រា ៨៨ និង មាត្រា ៩០ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សុធារិទ្ធ ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១០១ ឃ ចុះថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ។

៣- បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ វ៉េត សុធារិទ្ធ តាមនីតិវិធីច្បាប់។

៤- សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។ បើកសិទ្ធិប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំង គ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី 16 ខែ 6 ឆ្នាំ ២០១៤
**ក្រឡាបញ្ជី**
[redacted]

បានឃើញ
**ប្រធានសាលាឧទ្ធរណ៍**
[redacted]



Scanned with CamScanner